ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
លេខ: ០៧៤.............. សហអ

**សូមគោរពជូន**
**ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

<u>កម្មវត្ថុ:</u> *របាយការណ៍ស្តីពីការអនុវត្តន៍ការងាររបស់ DICO ក្នុងឆមាសទី១ ឆ្នាំ ២០១២*

*តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរព និង រាយការណ៍ ជូន* **ឯកឧត្តម ទេសរដ្ឋមន្ត្រី** *មេត្តាជ្រាបនូវរបាយការណ៍ ស្តីពីការអនុវត្តន៍ការងាររបស់ DICO ក្នុងរយៈពេល ៦ ខែដើម ឆ្នាំ ២០១២ មានដូចខាងក្រោម:*

I- **ការអនុវត្តន៍អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម** (Trade SWAp)

*ការអនុវត្តន៍អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម ក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០១២ យើងសម្រេចបាននូវសមិទ្ធិផលសំខាន់ៗដូចខាងក្រោម:*

- *អនុម័តផែនទីចង្អុលផ្លូវសម្រាប់សសរស្តម្ភ* (Pillar roadmap): *អនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម* SSC-TD-TRI (Sub-Steering Committee on Trade Development and Trade Related Investment) *បានអនុម័តជាឯកច្ឆ័ន្ទនូវផែនទីចង្អុលផ្លូវសម្រាប់សសរស្តម្ភ នៅក្នុងកិច្ចប្រជុំពេញអង្គរបស់ខ្លួនកាលពីថ្ងៃទី ១៧ កុម្ភៈ ២០១២ ។* Pillar roadmap *គឺជាឯកសារគោលក្នុងការអនុវត្តន៍* Trade SWAp *ដោយបានកំណត់ពីសូចនាករ ដើម្បីវាស់នូវកម្រិតជោគជ័យនៃការអនុវត្តន៍របស់* Trade SWAp ។

- អនុម័ត Project Approval Process Under TDSP): អនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម (SSC-TD-TRI)ក៏បានអនុម័តផងដែរនូវដំណើរការអនុម័តគម្រោង នៅក្នុងកម្មវិធី TDSP ។ ការរៀបចំដំណើរការនេះសំដៅ៖ (១) ផ្តល់អំណាច (Empower) និងការចូលរួម (Participation) ទៅដល់ក្រុមការងាររបស់សសរស្តម្ភទាំងបី, (២) ផ្តល់ភាពជាម្ចាស់ (Ownership) ដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ នៅក្នុងក្រុមការងារសសរស្តម្ភ, (៣) ជៀសវាងការលើកគម្រោងជាន់គ្នា ជាមួយស្ថាប័ននានានៅក្នុងក្រុមការងារសសរស្តម្ភ ។
- អនុម័តឲ្យមានការធ្វើបច្ចុប្បន្នភាព DTIS: យុទ្ធសាស្ត្រវិភាគសមាហរណកម្មពាណិជ្ជកម្ម DTIS (Diagnostic Trade Integration Strategy) ត្រូវបានអនុម័តកាលពីឆ្នាំ ២០០៧ ហើយយុទ្ធសាស្ត្រនេះត្រូវធ្វើបច្ចុប្បន្នភាពក្នុងរយៈពេល៥ឆ្នាំម្តង ។
- គម្រោង EIF Tier 2 CEDEP 2: SSC-TD-TRI បានអនុម័តជ្រើសរើសផ្នែកបីរួមមានៈ (១) ដំឡូងមី, (២) ទេសចរ, និង (៣) ជលផល ដើម្បីដាក់ទៅក្នុងគម្រោង EIF Tier 2 CEDEP 2 (Cambodia Export Diversification and Expansion Program – Part 2) ។ កម្មវិធី CEDEP 2 នេះគ្រោងនឹងបញ្ចប់ (Finalize) នៅក្នុងត្រីមាសទី៣ ឆ្នាំ ២០១២ ខាងមុខនេះ ។

ក)- **ក្រុមការងារសសរស្តម្ភទាំងបី:**

ក្រុមការងារសសរស្តម្ភទាំងបី បានកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំប្រចាំត្រីមាសរបស់ខ្លួនដោយយោងទៅតាម Benchmark របស់ធនាគារពិភពលោក ។ ក្រុមការងារសសរស្តម្ភទី១ និងទី៤ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ខ្លួន (សូមពិនិត្យរបាយការណ៍ជូនភ្ជាប់) ។

ខ)- **កិច្ចប្រជុំអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម SSC-TD-TRI (Sub-Steering Committee on Trade Development and Trade Related Investment)**

នៅក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០១២ នេះ DICO បានរៀបកិច្ចប្រជុំ SSC-TD-TRI ចំនួន ០២ លើក គឺនៅថ្ងៃទី ១៧ កុម្ភៈ ២០១២ និង ថ្ងៃទី ១៧ ឧសភា ២០១២ (សូមពិនិត្យរបាយការនៃកិច្ចប្រជុំទាំងពីរខាងលើ) ។

គ)- កិច្ចប្រជុំគណៈកម្មការអនុវត្តន៍ IC (Implementation Committee) :

DICO បានរៀបចំកិច្ចប្រជុំ IC យ៉ាងទៀងទាត់ ដូចដែលបានកំណត់នៅក្នុងតារាងកិច្ចប្រជុំប្រចាំឆ្នាំ សំដៅជំរុញការអនុវត្តន៍គម្រោង TDSP ឲ្យសម្រេចបានជោគជ័យ ។ នៅក្នុងឆមាសទី១ ឆ្នាំ ២០១២ នេះ DICO បានរៀបកិច្ចប្រជុំ IC ចំនួន ០៥ លើក (សូមពិនិត្យរបាយការណ៍ដូចមានជូនភ្ជាប់)។

II- **ការគ្រប់គ្រងជំនួយបច្ចេកទេស**

១)- កម្មវិធីគាំទ្រការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម (TDSP)

ក)- **វឌ្ឍនភាពនៃការអនុវត្តន៍គម្រោង:**

ក្នុងឆមាសទី១ ឆ្នាំ ២០១២ គម្រោង TDSP មានវឌ្ឍនៈភាពគួរឲ្យកត់សំគាល់ ដែលមានបណ្ដុចសំខាន់ៗដូចខាងក្រោម:

(i) នៅក្នុងជំនួយស្មារតី (Aide Memoire) របស់ខ្លួន ចុះថ្ងៃទី ០៥ មិនា ២០១២ ធនាគារពិភពលោក បានសម្រេចបង្កើនកម្រិតនៃការអនុវត្តន៍គម្រោងពី Moderately Satisfactory ទៅ Satisfactory Level ដែលជាកម្រិតខ្ពស់បំផុតនៅក្នុងប្រព័ន្ធដាក់ពិន្ទុរបស់ធនាគារពិភពលោក (World Bank Rating System) ។ គួរកត់សំគាល់ថា រយៈពេល ១៨ ខែដំបូងនៃការអនុវត្តន៍ គម្រោង TDSP ត្រូវបានគេដាក់ពិន្ទុនៅក្នុងកម្រិត Moderately Unsatisfactory ។



(ii) តាមការគ្រោងទុក គម្រោង TDSP នឹងត្រូវចប់នៅថ្ងៃទី ៣១ មិនា ២០១៦ ប៉ុន្តែដោយសារតែការអនុវត្តន៍គម្រោងនេះមានការយឺតយ៉ាវ នោះគម្រោង TDSP ត្រូវបានគេបន្តជាផ្លូវការឲ្យអនុវត្តរយៈពេល ២២ ខែបន្តទៀត គឺរហូតដល់ថ្ងៃទី ៣១ មករា ២០១៨ ។

(iii) **គម្រោង TDSP ត្រូវបានធនាគារពិភពលោក ជ្រើសរើសជាគម្រោងគំរូក្នុងការអនុវត្តន៍ Disclosure Element នៅក្នុង Good Governance Framework** ។ ការនេះគឺបានបង្ហាញពីតម្លាភាពក្នុងការអនុវត្តន៍គម្រោង និងបង្ហាញពីការទទួលខុសត្រូវ របស់មន្ត្រីអនុវត្តគម្រោងចំពោះសាធារណៈ ។

(iv) **គម្រោង TDSP បានពង្រឹងការងារតាមដាន និងវាយតំលៃ** (M&E) តាមរយៈការចុះត្រួតពិនិត្យការអនុវត្តការងាររបស់ IA ចំនួនបួន។ លើសពីនេះ International M&E Consultant ដែលបានចាប់ផ្តើមធ្វើការងារចាប់ពីថ្ងៃទី២០ ខែមិថុនា កំពុងបង្កើតឧបករណ៍សំខាន់ៗមួយចំនួន សំរាប់ការងារ M&E ។

ខ)- **អនុស្សរណៈនៃការយោគយល់គ្នា** (MoU):

(i) រយៈពេល ៦ ខែដើមឆ្នាំ ២០១៦ នេះ មិនមានគម្រោងថ្មីណាមួយត្រូវបានអនុម័តដោយ IC និង SSC-TD-TRI នោះទេ ។

(ii) មាន MoU ចំនួន ០៤ បាននិងកំពុងស្នើសុំកែសម្រួលថវិកា រួមមាន:

- ✓ គម្រោង Fishery Project របស់នាយកដ្ឋានជលផលត្រូវបានកែសម្រួលថវិកាពី $965,309 ទៅដល់ $1,262,708 ដោយត្រូវបញ្ចូល Output 5 បន្ថែមទៀត ។ ការកែសម្រួលថវិកានេះ ត្រូវបានទទួលការឯកភាពពីសំណាក់គណៈកម្មការអនុវត្តគម្រោង IC, SSC-TD-TRI និង World Bank ផងដែរ ។
- ✓ គម្រោង Rule of Origin របស់នាយកដ្ឋានពហុភាគី ត្រូវបានកែសម្រួលថវិកាពី $110,000 ទៅដល់ $303,045.75 ។ ការកែសម្រួលថវិកានេះ ត្រូវបានទទួលការឯកភាពពី IC, SSC-TD-TRI និង World Bank ផងដែរ ។
- ✓ គម្រោង Export Training របស់នាយកដ្ឋានជំរុញពាណិជ្ជកម្ម ត្រូវបានកែសម្រួលថវិកាពី $47,905 ទៅ ដល់ $54,899 ។ ការកែសម្រួលនេះបានទទួលការឯកភាពពី IC និង World Bank ។

- ✓ គម្រោង Value Chain របស់នាយកដ្ឋានជំរុញពាណិជ្ជកម្មបានស្នើកែប្រែថវិកាពី $263,208 ទៅដល់ $436,008 ។ ការកែសម្រួលនេះបានទទួលការឯកភាពគោលការ World Bank ហើយ IC បានផ្តល់ការឯកភាពដោយមានល័ក្ខខ័ណ្ឌ ថា DICO ចុះទៅធ្វើការត្រួតពិនិត្យនិងវាយតម្លៃគម្រោងនេះជាមុនសិន ហើយដាក់របាយការណ៍ជូន SSC ដើម្បីពិនិត្យសំរេច ។
- ✓ គម្រោងរបស់ CDC បានកែសម្រួលថវិកាពី $195,860 ទៅ $205,620 ។ ការកែសម្រួលនេះបានទទួលការឯកភាពពី World Bank ។

(iii) អនុស្សារណៈនៃការយោគយល់គ្នាចំនួន ៤ បានធ្វើវិសោធនកម្មចប់សព្វគ្រប់ ក្នុងនោះរួមមាន DTSI, D/IPR, CAMCONTROL, GDIT ។ MoU គម្រោងចំនួន៥ របស់ GDCE និង ISC ត្រូវបានចុះហត្ថលេខាដោយនាយកគម្រោង IAs ហើយនឹងដាក់ជូនប្រធាន IC ពិនិត្យសំរេច ។

(iv) គម្រោងចំនួនមួយបានបញ្ចប់ដោយនាយកដ្ឋានជំរុញពាណិជ្ជកម្ម គឺគម្រោង Top Ten Products ។ ដោយឡែកគម្រោងរបស់នាយកដ្ឋានបុគ្គលិកគ្រោងនឹងបញ្ចប់ក្នុងពេលឆាប់ៗខាងមុខនេះ ។

**គ)- ការងារហិរញ្ញវត្ថុ:**

**គ១). ការចំណាយក្នុងត្រីមាសទី១ ឆ្នាំ ២០១២**

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១២ យើងបានចំណាយចំនួន $633,515 បើគិតជាភាគរយមានចំនួន 69% នៃផែនការថវិកាប្រចាំត្រីមាសទី១ ដែលមានទឹកប្រាក់ ចំនួន $920,606 ។ ដោយសារមានការខ្វះខាតថវិកានៅក្នុងគណនីរបស់ TDSP, DICO មិនបានធ្វើការចំណាយនូវថវិកាចំនួន $135,000 នៅក្នុងត្រីមាសទី១ នេះ ។ ទាក់ទងទៅនឹងការចំណាយនៅក្នុងត្រីមាសទី១ នេះ មានចំណុចពីរគួរឲ្យកត់សំគាល់ដូចខាងក្រោម:

- អត្រាចំណាយក្នុងត្រីមាសទី១ នេះអាចកើនឡើងរហូតដល់ 83.4% នៃផែនការថវិកាក្នុងត្រីមាសទី១ ឬស្មើនឹង $768,515 ប្រសិនបើ TDSP មានថវិកាគ្រប់គ្រាន់នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១២ ។

• ការខ្វះខាតថវិកានេះគឺអាស្រ័យដោយនីតិវិធី Recover របស់ធនាគារពិភពលោកនៅ មុនពេលចប់គម្រោងនីមួយៗ ។

| តារាងផែនការថវិកា និង ការចំណាយជាក់ស្តែងក្នុងត្រីមាសទី ១ ឆ្នាំ ២០១២ | | | | |
|---|---|---|---|---|
| No. | Disbursement Categories | Budget | Actual | Variance |
| | | US$ | US$ | US$ |
| 1 | Goods | 286,412 | 92,941 | 193,471 |
| 2 | Consultants Service | 480,968 | 458,071 | 22,897 |
| 3 | Training, W/Shop & Study Tours | 82,291 | 28,734 | 53,557 |
| 4 | Incremental Operating Cost | 52,335 | 36,971 | 15,364 |
| 5 | Priority Operating Cost | 18,600 | 16,798 | 1,802 |
| TOTAL | | **920,606** | **633,515** | **287,091** |

ដ្យាក្រាមបង្ហាញពីការចំណាយតាមត្រីមាសនៅឆ្នាំ ២០១១ និង ២០១២ របស់គម្រោង TDSP




គ២). ការចំណាយក្នុងត្រីមាសទី២ ឆ្នាំ ២០១២

- នៅក្នុងត្រីមាសទី២ ឆ្នាំ ២០១២ (គិតត្រឹមខែមេសា និងឧសភា) យើងបានចំណាយចំនួន $470,797 បើគិតជាភាគរយមានចំនួន 64.6% នៃផែនការថវិកាប្រចាំត្រីមាសទី ២ ដែលមានទឹកប្រាក់ ចំនួន $727,952 ។
- តួលេខខាងលើនេះគឺគ្រាន់តែក្នុងរយៈពេលពីរខែក្នុងត្រីមាសទី២ ប៉ុណ្ណោះ ហើយយើងសង្ឃឹមថារហូតដំណាច់ត្រីមាសទី២ យើងនឹងសម្រេចបានតាមផែនការ ។

| តារាងផែនការថវិកា និង ការចំណាយជាក់ស្តែងក្នុងត្រីមាសទី ២ (មេសា-ឧសភា) ឆ្នាំ ២០១២ | | | | |
|---|---|---|---|---|
| No. | Disbursement Categories | Budget | Actual | Variance |
| | | US$ | US$ | US$ |
| 1 | Goods | 54,900 | 140,660 | -85,760 |
| 2 | Consultants Service | 511,424 | 272,155 | 239,269 |
| 3 | Training, W/Shop & Study Tours | 92,702 | 30,165 | 62,537 |
| 4 | Incremental Operating Cost | 50,327 | 17,530 | 32,798 |
| 5 | Priority Operating Cost | 18,600 | 10,287 | 8,313 |
| TOTAL | | **727,952** | **470,797** | **257,155** |

គ៣). **ការចំណាយក្នុងរយៈពេល ៥ ខែដើមឆ្នាំ ២០១២**

- ក្នុងរយៈពេល ៥ខែដើមឆ្នាំ ២០១២ (មករា-ឧសភា) យើងបានចំណាយចំនួន $1,104,311 បើគិតជាភាគរយមានចំនួន 66.9% នៃផែនការថវិកាប្រចាំឆមាសទី១ ឆ្នាំ ២០១២ ដែលមានទឹកប្រាក់ ចំនួន $1,648,558 ។
- រហូតដល់ដំណាច់ខែមិថុនា ២០១២ យើងរំពឹងថា រហូតដំណាច់ត្រីមាសទី២ យើងនឹងសម្រេចបានតាមផែនការដែលបានគ្រោងទុក ។

| តារាងផែនការថវិកា និង ការចំណាយជាក់ស្តែងក្នុងរយៈពេល៥ខែ (មករា-ឧសភា) ឆ្នាំ ២០១២ | | | | |
|---|---|---|---|---|
| No. | Disbursement Categories | Budget | Actual | Variance |
| | | US$ | US$ | US$ |
| 1 | Goods | 341,312 | 233,601 | 107,711 |
| 2 | Consultants Service | 992,392 | 730,226 | 262,166 |
| 3 | Training, W/Shop & Study Tours | 174,992 | 58,899 | 116,093 |
| 4 | Incremental Operating Cost | 102,662 | 54,500 | 48,162 |
| 5 | Priority Operating Cost | 37,200 | 27,085 | 10,115 |
| TOTAL | | **1,648,558** | **1,104,311** | **544,247** |

គ៤). **ស្ថានភាពរួមនៃថវិកាកម្មវិធី TDSP គិតត្រឹមថ្ងៃទី ៣១ មីនា ២០១២:**

- ថវិកាចំនួន $6,070,500 ដែលស្មើនឹង 49.16% នៃចំនួនថវិកាសរុប ($12.36m) គឺជាថវិកាដែលមាននៅក្នុង MoU ជាមួយភ្នាក់ងារអនុវត្តគម្រោងទាំង ១៤ ។
- ថវិកាចំនួន $3,040,600 ដែលស្មើនឹង 24.62% នៃចំនួនថវិកាសរុប ($12.36m) គឺជាដែលយើងបានចំណាយសរុបគិតត្រឹមថ្ងៃទី ៣១ មីនា ២០១២ ។
- យើងត្រៀមបំរុងថវិកាចំនួន $900,000 សម្រាប់ប្រតិបត្តិការរបស់ DICO ក្នុងរយៈពេល ២២ ខែ គឺរហូតដល់ថ្ងៃទី ៣១ មករា ២០១៤ ដូច្នេះថវិកាដែលនៅសល់សម្រាប់គម្រោងថ្មីៗ ទៀតគឺមានចំនួនតែ $2.34m ប៉ុណ្ណោះ ។




ឃ)- ការងារលទ្ធកម្ម:

គិតរហូតដល់ថ្ងៃទី ៣១ ឧសភា ២០១២ យើងបានធ្វើលទ្ធកម្មចំនួន 97.1% បើប្រៀបធៀបទៅនឹងការដាក់កំណត់ (Benchmark) របស់ធនាគារពិភពលោក ដែលមានទឹកប្រាក់ចំនួន $4.5m រហូតដល់ដំណាច់ត្រីមាសទី២ ឆ្នាំ ២០១២ ។

តារាងបង្ហាញពីវឌ្ឍនភាពក្នុងការធ្វើលទ្ធកម្ម គិតត្រឹមថ្ងៃទី ១១ ឧសភា ២០១២

| Procurement Progress as of 31 May 2012 | | | | |
|---|---|---|---|---|
| Benchmark by end of Q2-2012: $4,500,000 | | | | |
| Actual: | | | | |
| No | Type of Contract | Actual Achievement (USD) as of 31 May 2012 | TOTAL | % against benchmark |
| 1 | Goods | 888,449.69 | 4,373,293.69 | 97.1% |
| 2 | Consultant services | 3,484,844.00 | | |
| Projection: | | | | |
| No | Type of Contract | Actual Achievement (USD) as of 30 Jun 2012 | TOTAL | % against benchmark |
| 1 | Goods | 982,702.69 | 4,839,684.69 | 107.5% |
| 2 | Consultant services | 3,856,982.00 | | |

មានកញ្ចប់លទ្ធកម្មចំនួន ៦ ដែលមានការយឺតយ៉ាវក្នុងការធ្វើលទ្ធកម្ម:

- ICT Master Plan (System - hardware & software and office equipment) សំរាប់គម្រោងរបស់អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម ដែលមានកញ្ចប់លទ្ធកម្មចំនួន ៤ ហើយត្រូវធ្វើលទ្ធកម្មដោយក្រុមហ៊ុន CKP ។
- UNIDO Consultant Services សំរាប់គម្រោងរបស់រដ្ឋបាលជលផល នៃក្រសួងកសិកម្ម ។ DICO កំពុងរៀបចំលិខិតជាផ្លូវការទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីស្នើសុំធ្វើលទ្ធកម្មតាមនីតិវិធី SSS (Single Source Selection) ។
- International and national consultants for RSA: គណៈកម្មការលទ្ធកម្មបានជ្រើសរើសទីប្រឹក្សាជាតិម្នាក់ និងទីប្រឹក្សាអន្តរជាតិម្នាក់រួចហើយ ចំណែកទីប្រឹក្សាចំនួន ៣ នាក់ទៀតគឺស្ថិតនៅក្នុងដំណើរការលទ្ធកម្ម ។

**ង)- ការងារបណ្តុះបណ្តាល និងការរៀបចំសិក្ខាសាលា:**

✓ រួមជាមួយនិងកិច្ចប្រជុំប្រចាំខែរវាង DICO និង IAs យើងបានរៀបចំវគ្គបណ្តុះបណ្តាល ការងារលទ្ធកម្ម (Procurement Orientation) និងនីតិវិធីហិរញ្ញវត្ថុ នៅថ្ងៃទី ២៧ មេសា ២០១២ ដល់ IAs ហើយនេះក៏ជាការបំពេញតាម Benchmark ទី ១៩ របស់ធនាគារពិភពលោកផងដែរ ។

✓ កាលពីថ្ងៃទី ២៥ ឧសភា ២០១២ នៅទីរួមខេត្តមណ្ឌលគិរី នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DICO) បានរៀបចំសិក្ខាសាលារយៈពេលពេញមួយថ្ងៃ ដើម្បីផ្សព្វ

ផ្សាយអតិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម Trade SWAp (Trade Sector Wide Approach) ។ នេះជាការរៀបចំសិក្ខាសាលាលើកទី១ ក្នុងចំណោមសិក្ខាសាលាចំនួន ៤ ដែលបានកំណត់នៅក្នុងផែនការការងារ (Work Plan) របស់ DICO នៅក្នុងឆ្នាំ ២០១២ ។

ច)- ផ្នែកទ្រទ្រង់គម្រោង:

រៀបចំបែងចែកការងារមន្ត្រី LO សាជាថ្មី តាមតារាងដូចខាងក្រោម ។ ការរៀបចំនេះ គឺដោយសារតែមានមន្ត្រី LO ចំនួនពីរនាក់បានផ្លាស់ចេញពីនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមានមន្ត្រី LO ម្នាក់បានទទួលអាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេស ។

| លរ | ឈ្មោះ | ទទួលខុសត្រូវគម្រោង | ទំនាក់ទំនង |
|---|---|---|---|
| ១ | ឃ្លឹង ឌូរ៉ា<br>Khloeung Doura | GDCE, IP, MUL | doura_k007@yahoo.com<br>016-935-422 |
| ២ | ម៉ៅ ឆៃហៀង<br>Moa Chhay Heang | TPD, LAD, DoP | heang017@gmail.com<br>017-571-119 |
| ៣ | ឡាយ សុផល<br>Lay Sophal | Camcontrol, ISC, DTSI | sophal97@gmail.com<br>016-862-529 |
| ៤ | ហុង ប៊ុនសេង<br>Hong Bunseng | RSA, CDC | hongbunseng@gmail.com<br>092-86-86-96 |
| ៥ | ប៉ូ រតនា<br>Po Rathana | FiA, GDIT | rathana.po@gmail.com<br>011-60-50-45 |

ឆ)- ការអនុវត្តន៍ Benchmarks របស់ធនាគារពិភពលោក:

តាមរយៈជំនួយស្មារតីរបស់ខ្លួនចុះថ្ងៃទី ០៥ មិនា ២០១២ ធនាគារពិភពលោកបានដាក់ Benchmark ចំនួន ២៦ ចំណុច ក្នុងនោះ Benchmark ទី៦ និង ទី ៨ គេតម្រូវឲ្យមានការតែងតាំងមន្ត្រីពីររូប ទី១គឺ Senior Official as a focal point for Strategic Guidance និងទី២គឺ TDSP

Project Manager ។ **ឯកឧត្តម ទេសរដ្ឋមន្ត្រី** បានធ្វើការណែនាំឲ្យពិនិត្យឯកសារនេះឡើងវិញឲ្យបានចាប់បំផុត ។ ចំណែកវឌ្ឍនភាពនៃការអនុវត្តន៍ Benchmark ដ៏ទៃទៀតគឺដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ។

**ជ)- កិច្ចប្រជុំប្រចាំខែរវាង DICO និង IAs:**

DICO បានរៀបចំយ៉ាងទៀងទាត់នូវកិច្ចប្រជុំប្រចាំខែរវាង DICO និង IAs ក្នុងគោលបំណងស្វែងយល់អំពីការប្រឈម, ភាពងាយស្រួល និង ផ្សព្វផ្សាយនូវលទ្ធផលនានាដែលកើតចេញពីការអនុវត្តន៍គម្រោង TDSP ។ ក្រៅពីនេះ DICO បានដាក់បញ្ចូលនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំនូវវគ្គបណ្តុះបណ្តាលនានា ដែលមានការទាក់ទងទៅនឹងការអនុវត្តន៍គម្រោង ដូចជា: វគ្គបណ្តុះបណ្តាលការងារលទ្ធកម្ម វគ្គបណ្តុះបណ្តាលក្នុងគ្រប់គ្រងហិរញ្ញវត្ថុ និង វគ្គបណ្តុះបណ្តាលក្នុងការងារត្រួតពិនិត្យនិងវាយតម្លៃ M&E (Monitoring and Evaluation) ផងដែរ ។

**ឈ)- ប្រតិបត្តិការចំណាយអាទិភាព POC (Priority Operating Cost):**

កាលពីថ្ងៃទី ០៨ សីហា ២០១១ យើងបានចុះកិច្ចសន្យាជាមួយមន្ត្រីដែលទទួលបាន POC ទាំងអស់ ហើយនៅថ្ងៃទី ១៣ កញ្ញា ២០១១ មន្ត្រី POC ទាំងអស់ទទួលបានប្រាក់ POC លើកដំបូងនៅក្នុងគណនីរបស់ខ្លួន ដែលគេចាប់គណនាពីថ្ងៃទី ១៦ ឧសភា ២០១១ ។ ទាំងធនាគារពិភពលោក និងប្រទេសផ្តល់ជំនួយ បានបញ្ជាក់យ៉ាងច្បាស់ថា ប្រតិបត្តិការចំណាយអាទិភាពនឹងត្រូវបញ្ចប់ចាប់ពីថ្ងៃទី ០១ កក្កដា ២០១២ ខាងមុខនេះតទៅ ។

**ញ)- របាយការណ៍របស់សវនកម្ម**

ញ១). ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានជួលក្រុមហ៊ុនសវនកម្មអន្តរជាតិ Ernst & Young ឲ្យមកធ្វើសវនកម្មគម្រោងទាំងពីរគឺ TDSP និង EIF ។ ចំណុចសំខាន់ក្នុងការធ្វើសវនកម្មនេះមានដូចខាងក្រោម:

- តម្លៃ: - គម្រោង TDSP: $4,840
  - គម្រោង EIF: $1,650
- រយៈពេលធ្វើសវនកម្ម: ០១ មករា ដល់ ៣១ ធ្នូ ២០១១
- បានផ្ញើរបាយការណ៍ទៅធនាគារពិភពលោកនៅថ្ងៃទី ១៤ មិថុនា ២០១២

✓ បែបបទហិរញ្ញវត្ថុរបស់គម្រោងត្រូវបានរៀបចំឡើងទៅតាមបទដ្ឋានគណនេយ្យ
✓ បែបបទហិរញ្ញវត្ថុត្រូវបានរៀបចំទៅតាមសេចក្តីត្រូវការរបស់គម្រោង

៣៣). ក្រៅពីនោះ សវនករបានរកឃើញនូវចំណុចខ្វះខាតតូចតាចមួយចំនួន មានដូចខាងក្រោម:

- **ការបង់ពន្ធលើប្រាក់បៀវត្សរបស់ទីប្រឹក្សា:** កម្មវិធី TDSP មិនបានត្រៀមថវិកា និងនីតិវិធីសម្រាប់ដោះស្រាយបញ្ហានេះទេ ។ **អនុសាសន៍របស់សវនករ:** ក្រសួងពាណិជ្ជកម្ម ស្នើសុំការបញ្ជាក់ជាផ្លូវការពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានពន្ធដារ) ក្នុងបញ្ហានេះ ។
- **ការទូទាត់ប្រាក់បៀវត្សរបស់ទីប្រឹក្សាជាតិ:** DICO បានទូទាត់ប្រាក់បៀវត្សលើសចំនួនជាក់ស្តែង ជូនលោក Ly Sophearith ទីប្រឹក្សាជាតិ បំរើការឲ្យនាយកដ្ឋានស្ថិតិ ។ បញ្ហានេះត្រូវបានដោះស្រាយចប់សព្វគ្រប់ ដោយ លោក Ly Sophearith បានសងប្រាក់ដែលលើសនោះមក TDSP វិញរួចហើយ ។
- **ការយឺតយ៉ាវក្នុងការពិនិត្យអចលនទ្រព្យរបស់គម្រោង:** នៅដំណាច់ឆ្នាំ ២០១២ DICO មានការយឺតយ៉ាវ ក្នុងការចុះត្រួតពិនិត្យអចលនទ្រព្យ នៅតាមភ្នាក់ងារអនុវត្តន៍គម្រោងនីមួយៗ ។
- **មិនមានបញ្ជីអ្នកកាន់កាប់អចលនទ្រព្យ:** នាយកដ្ឋាននីតិកម្មមិនបានផ្តល់ទាន់ពេលវេលានូវបញ្ជីអ្នកកាន់កាប់អចលនទ្រព្យនៅក្នុងគម្រោងរបស់ខ្លួន ។
- **ការយឺតយ៉ាវក្នុងការបិទលេខកូដអចលនទ្រព្យ:** DICO មានការយឺតយ៉ាវក្នុងការបិទលេខកូដអចលនទ្រព្យនៅក្នុងនាយកដ្ឋានរដ្ឋបាល នៃក្រសួងពាណិជ្ជកម្ម (Conference system) ។

២)- គម្រោងសមាហរណកម្មពាណិជ្ជកម្ម EIF (Enhanced Integrated Framework)

**ក)- វឌ្ឍនភាពសំខាន់ៗក្នុងឆមាសទី១ ឆ្នាំ ២០១២:**

នៅក្នុងត្រីមាសទី ១ ឆ្នាំ ២០១២ ការអនុវត្តន៍គម្រោង EIF Tier 1 មានវឌ្ឍនភាពសំខាន់ៗដូចខាងក្រោម:

- បានដាក់ជូន UNOPS ទាន់ពេលវេលានូវផែនការការងារនិងផែនការថវិកាឆ្នាំ២០១២
- ផែនការបណ្តុះបណ្តាលក៏បានដាក់ជូន UNOPS ផងដែរ ដែល UNOPS គ្រោងនឹងយកគំរូផែនការបណ្តុះបណ្តាលរបស់កម្ពុជា ទៅអនុវត្តនៅប្រទេសផ្សេងទៀត ។
- បានបញ្ជូនមន្ត្រី DICO ទៅចូលរួម NIU-Exchange Program នៅប្រទេស ឡាវ កាលពីថ្ងៃទី ២៦ ដល់ ២៧ មករា ២០១២ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ក្នុងការអនុវត្តន៍គម្រោង EIF Tier 1 ។
- បានទទួលបេសកកម្មត្រួតពិនិត្យចំនួនពីរលើក គឺលើកទី១ធ្វើឡើងដោយ UNOPS-TFM កាលពីថ្ងៃទី ១៩ ដល់ ២១ មីនា ២០១២ ដោយផ្តោតទៅលើការអនុវត្តន៍គម្រោង EIF Tier 1 និងលើកទី២គឺធ្វើឡើងដោយ EIF-ES កាលពីថ្ងៃទី ០៩ ដល់ ១២ មេសា ២០១២ ដោយផ្តោតទៅលើការលើកគម្រោង EIF Tier 2 (CEDEP1) ។
- បានបញ្ចប់ (Finalized) គម្រោង EIF Tier 2 ជំហ៊ានទី១ (CEDEP 1 – Cambodia Export Diversification Expansion Program - Part 1) ។ គម្រោងនេះមានបីផ្នែក (Components) ដូចខាងក្រោម:
    - អង្ករ អនុវត្តគម្រោងដោយ (IFC)
    - សូត្រ អនុវត្តគម្រោងដោយ (ITC)
    - ត្រួតពិនិត្យនិងវាយតម្លៃ អនុវត្តគម្រោងដោយ (DICO-NIU)
    - ចាប់ផ្តើមអនុវត្តគម្រោង: ០១ កក្កដា ២០១២
    - រយៈពេលអនុវត្តគម្រោង: ៣ ឆ្នាំ
    - ថវិកាសរុបរបស់គម្រោង: $3,288,766
    - ថវិកាស្នើសុំពី EIF-ES: $2,313,051
- បានរៀបចំកិច្ចប្រជុំ TAC 2 Meeting កាលពីថ្ងៃទី ០៣ ឧសភា ២០១២: គោលបំណងសំខាន់ក្នុងការរៀបចំកិច្ចប្រជុំនេះ គឺសំដៅប្រមូលការគាំទ្រពីសំណាក់ដៃគូរអភិវឌ្ឍន៍នូវគម្រោង EIF Tier 2 (CEDEP 1) ដែលនេះជាបុរេលក្ខខ័ណ្ឌមួយក្នុងការបញ្ជូន (Submit) គម្រោងនេះទៅលេខាធិការដ្ឋាន EIF ។

- SSC-TD-TRI បានអនុម័តគម្រោង EIF Tier 2 (CEDEP 2) ដោយជ្រើសរើសគម្រោងបី គឺ:
  - ដំឡូងមី អនុវត្តគម្រោងដោយ (UNDP)
  - ទេសចរ អនុវត្តគម្រោងដោយ (Shift 360)
  - ជលផល អនុវត្តគម្រោងដោយ (UNIDO)
  - ថវិកាប៉ាន់ស្មាន: $3 million ក្នុងរយៈពេល ៣ ឆ្នាំ
  - គ្រោងចាប់ផ្តើមអនុវត្ត: ០១ កញ្ញា ២០១៦
- បានធ្វើវិសោធនកម្ម MoU ជាមួយ UNOPS ចុះថ្ងៃទី ២៣ ឧសភា ២០១៦

ខ)- **ការងារលទ្ធកម្ម:**

✓ ការជ្រើសរើសទីប្រឹក្សា: ទីប្រឹក្សាចំនួន ២ រូបត្រូវបានជ្រើសរើសឲ្យមកបំពេការងារនៅក្នុងគម្រោង EIF៖
  - National Administration Assistant, Mrs. Phat Sothery full time consultant;
  - International Trade SWAp Review Consultant, Mr. Shumon KHALID, part time consultant.

✓ បានបន្តកិច្ចសន្យាជូន Mrs. Tep Borita ក្នុងរយៈពេលមួយឆ្នាំទៀត ។

✓ បានកែសម្រួល TOR និងបន្តកិច្ចសន្យារបស់លោក Sven Callebaut ដោយបង្កើនចំនួនថ្ងៃធ្វើការពី ៨០ ថ្ងៃ ដល់ ១២០ ថ្ងៃ ។

គ)- **ការអនុវត្តន៍តាម** Joint Recommendations:

បេសកកម្មត្រួតពិនិត្យទាំងពីរលើកគឺ UNOPS-TFM និង EIF-ES បានដាក់ចេញនូវ Joint Recommendations សម្រាប់ឲ្យ DICO-NIU អនុវត្ត ។ មាន Recommendations ចំនួនពីរ ដែលត្រូវយកចិត្តទុកដាក់ជាពិសេស:

- Recommendation ទី៤: ទាក់ទងទៅនឹងការអនុវត្តន៍នីតិវិធីលទ្ធកម្ម (Procurement Procedures) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- Recommendation ទី៩: ទាក់ទងទៅនឹងការអនុវត្តន៍ Financial Management Manual (FMM) & Standard Operation Procedures (SOP) ដែលសំដៅទៅលើការអនុវត្តន៍សេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម លេខ: 131 MoC/SM 2009 ចុះថ្ងៃទី ១៥ មិថុនា ២០០៩ ។

**ឃ)- ការងារថវិកា:**

**ឃ១). ការចំណាយក្នុងត្រីមាសទី១ ឆ្នាំ ២០១២**

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១២ យើងបានធ្វើការចំណាយតែចំនួន 43.2% នៃចំនួនថវិកាដែលបានគ្រោងទុក ។

| តារាងផែនការថវិកា និង ការចំណាយជាក់ស្តែងក្នុងត្រីមាសទី ១ ឆ្នាំ ២០១២ | | | | |
|---|---|---|---|---|
| No. | Disbursement Categories | Budget | Actual | Variance |
| | | US$ | US$ | US$ |
| 1 | Goods | 11,380 | 9,251 | 2,165 |
| 2 | Consultants Service | 64,404 | 28,236 | 36,168 |
| 3 | Training, W/Shop & Study Tours | 50,758 | 15,151 | 35,607 |
| 4 | Incremental Operating Cost | 2,975 | 3,438 | -463 |
| 5 | Priority Operating Cost | - | - | - |
| TOTAL | | **129,517** | **56,076** | **73,441** |

**ឃ២). ការចំណាយក្នុងត្រីមាសទី២ (មេសា-ឧសភា) ឆ្នាំ ២០១២**

នៅក្នុងត្រីមាសទី២ (មេសា-ឧសភា) ឆ្នាំ ២០១២ យើងបានធ្វើការចំណាយតែចំនួន 45.0% នៃចំនួនថវិកាដែលបានគ្រោងទុក ។

| តារាងផែនការថវិកា និង ការចំណាយជាក់ស្តែងក្នុងត្រីមាសទី ២ (មេសា-ឧសភា) ឆ្នាំ ២០១២ | | | | |
|---|---|---|---|---|
| No. | Disbursement Categories | Budget | Actual | Variance |
| | | US$ | US$ | US$ |
| 1 | Goods | 28,450 | 25,617 | 2,833 |
| 2 | Consultants Service | 64,404 | 25,200 | 39,204 |
| 3 | Training, W/Shop & Study Tours | 50,758 | 11,567 | 39,191 |
| 4 | Incremental Operating Cost | 2,975 | 3,717 | -742 |
| 5 | Priority Operating Cost | - | - | - |
| TOTAL | | **146,587** | **66,101** | **80,486** |